# មេរៀនទី ១

# Introduction PHP

## History

PHP ត្រូវបានផ្តល់ឈ្មោះជាផ្លូវការ HyperText Preprocessor វាជាភាសាដែលតំណើរការនៅលើ Serverដែលជា ទូទៅត្រូវបាន សរសេរក្នុងបរិបទ HTML ប៉ុន្តែមិនដូចជា HTML page ធម្មតានោះទេPHP script មិនត្រូវបានបញ្ជូន ទៅអោយ client ដោយ server ផ្ទាល់នោះទេ វាធ្វើការបញ្ជូនដោយ PHP engine ។ PHP code ដែលឋិតនៅក្នុង script អាចប្រើដើម្បីធ្វើការជាមួយ Databases, បង្កើតជារូបភាព ,អាន និងបញ្ចូលទិន្នន័យឬ កែរប្រែអត្ថបទដែលមាននៅខាងក្នុង files ឬ ធ្វើការទំនាក់ទំនងទៅកាន់ Remote Server ព្រមជាមួយនឹងលទ្ធភាពជាច្រើនផ្សេងទៀត ។

Rasmus Lerdorf គឺជាមនុស្សដំបូងដែលអភិវឌ្ឍន៍នូវ PHP/FI ហើយត្រូវបានមនុស្សរាប់លានអ្នកប្រើប្រាស់វា ។ ជំនាន់តំបូងនៃ PHP/FI ឈ្មោះថា **Personal Homepage Tools/Form Interpreter**ដែលលក្ខណៈជាមូលដ្ឋានគឺស្រដៀងទៅនឹងភាសា Perl ព្រោះបានប្រមូលផ្តុំនូវ Perl scripts មកអភិវឌ្ឍន៍ នៅក្នុងអំឡុងឆ្នាំ ១៩៩៥ ប៉ុន្តែវានៅមានកង្វះខាតជាច្រើននៅក្នុងភាសានេះ ដូចជា for loops ជាដើម ។

## PHP/FI 2

នៅក្នុងឆ្នាំ ១៩៩៧ Rasmus បន្តការអភិវឌ្ឍន៍នូវ PHP/FI 2 រហូតមកដល់ខែ វិច្ឆិកា ឆ្នាំដដែលបន្ទាប់ពី Andi Gutmans ហើយនិង Zeev Suraski បានប្រទះឃើញនូវ PHP/FI ចំពេលដែលពួកគេកំពុងស្វែងរកនូវភាសាដើម្បីអភិវឌ្ឍន៍នូវគំរោងបង្កើត E-commerce solution សំរាប់សកលវិទ្យាល័យ របស់ពួកគេ ។ ពួកគេបានអោយដឹងថា PHP/FI ពុំទាន់មានលទ្ធភាពគ្រប់គ្រាន់នៅឡើយហើយខ្វះខាតនូវ លក្ខណៈពិសេសជាច្រើន ។ ចំនុចមួយដែលមានការចាប់អារម្មណ៍ជាងគេ គឺ while loops ដែលពួកគេនឹងត្រូវប្រតិបត្តិ ។

## PHP 3

Zeev and Andi សំរេចចិត្តសរសេរ scripting language ឡើងវិញប៉ុន្តែពុំវត្តមាន Rasmusចូលរួមដើម្បីអភិវឌ្ឍន៍នូវ PHP3ឡើយហើយបានផ្តល់នូវឈ្មោះថ្មីថា**Hypertext Preprocessor**ដើម្បីបញ្ជាក់ថា PHPគឺជាផលិតផលផ្សេងមួយទៀតហើយនឹងមិនត្រឹមតែយកមកប្រើសំរាប់តែការងារផ្ទាល់ ខ្លួននោះទេ ។ Zeev and Andi ក៏បានបង្កើតនូវ Extension API ដែល API បង្កើតថ្មីនេះវាមានលទ្ធភាពបំពេញនូវការងារជាច្រើនដូចជា Accessing databases , spell checkers ហើយនឹង បច្ចេកវិទ្យាដទៃៗទៀត ដែលធ្វើអោយមានការចាប់អារម្មណ៍ពីសំណាក់អ្នកអភិវឌ្ឍន៍ ជាច្រើនមកចូលរួមក្នុងគំរោង PHP ។ នៅខណៈពេលនោះដែរ PHP ក៏ត្រូវបានបញ្ចេញនូវជំនាន់ថ្មីរបស់ខ្លួនគឺ PHP 3 នៅ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៩៨ ដែលតាមការប៉ាន់ស្មាន PHP នឹងត្រូវបានតំឡើង ប្រមាណ ជាង ៥0 000 domains ប៉ុន្តែជាមួយតួលេខពិតប្រាកដ លើកដំបូងរបស់ PHP ត្រូវបានគេតំឡើងច្រើនជាងមួយលាន Domain ទៅទៀត ។

**PHP 4**

នៅក្រោយឆ្នាំ ១៩៩៨ Zeev និង Andi ងាកទៅពិតនិត្យលើការងារ PHP 3 ហើយពួកគេមានគំនិតថាពួកគេអាចសរសេរនូវ script language ឡើងវិញអោយមានលក្ខណៈល្អប្រសើរជាងមុនទៅទៀត ក្នុងខណៈពេលដែល PHP 3 កំពុងបន្តការធ្វើសម្ព័ន្ធ និងប្រតិបត្តិការនោះ PHP 4 ក៏ ចាប់ផ្តើមបង្កើតនូវគំរូថ្មី គឺ "compile first, execute later." តំណាក់កាលនៃការ compile មិនត្រូវបាន complie PHP Script អោយទៅជា machine code នោះទេ វាជំនួសដោយការ compile ទៅជា byte code ដែលធ្វើ ការប្រតិបត្តិការ ដោយ **Zend Engine** ( Zend មកពីពាក្យថា **Zeev** និង **Andi** ) ។ វិធីសាស្រ្តថ្មីសំរាប់ការប្រតិបត្តិ script នេះអាចធ្វើអោយ PHP 4 តំណើរការបានល្អប្រសើរច្រើនជា PHP 3 ហើយត្រូវបានដាក់បង្ហាញនូវ PHP 4 នេះក្នុង ខែ ឧសភា ឆ្នាំ ២០០២ ប៉ុន្តែដោយមានការផ្លាស់ប្តូរនៅក្នុងភាសានេះជាបន្តបន្ទាប់ទើប PHP 4 បានបង្កើតនូវជំនាន់របស់ខ្លួន ជា PHP 4.1.0 នឹង បានបង្ហាញនូវ **Superglobals** ដូចជា $_GET និង $_POST ។ ដែល Superglobals នេះអាចយកមកប្រើប្រាស់ពីខាងក្នុង Functions ដោយមិនចាំបាច់ប្រើ global keyword ។ រហូតដល់ជំនាន់ចុងក្រោយរបស់ PHP4ត្រូវបាន បង្ហាញ ជាចុងក្រោយបង្អស់ នៅថ្ងៃទី 27 ខែ ធ្នូ ឆ្នាំ ២០០២ ។

**PHP 5**

ដោយមានតំរូវការជាច្រើននូវលក្ខណៈរបស់ object-oriented Andi ក៏មានគំនិតសរសេរនូវObject-Oriented សំរាប់ជាផ្នែកនៃ Zend Engine. Zeev and Andi បានសរសេរនូវឯកសារអំពី " Zend Engine II : Feature Overview and Design " ហើយចាប់ផ្តើមពិភាក្សាគ្នាអំពី PHP's ទៅថ្ងៃអនាគតដែលក្នុងជំនាន់ PHP 5 មានចំនុចជាច្រើនដែលនឹងត្រូវកែប្រែ បន្ថែម ឬ រំលោះចោល ។
PHP's មិនត្រឹមតែប្រែប្រួលដោយអាចអោយប្រើប្រាស់នូវលក្ខណៈ Object-Oriented ប៉ុណ្ណោះនោះទេ វាថែមទាំង ផ្ទុកនូវមុខងារថ្មីៗជាច្រើនដែលបញ្ចូលជាមួយមុខងារសំរាប់ XML ហើយជាពិសេសនោះ គឺ SimpleXML extension ដែលធ្វើអោយមានភាពងាយស្រួល ក្នុងការសម្របសម្រួលជាមួយឯកសារ XML និង SOAP ឬ MySQLi ថ្មី ហើយនឹង extensions ផ្សេងៗទៀតដែលជាចំនុចសំខាន់នៅក្នុង PHP's ។ គេរំពឹងថា PHP 5 នឹងអាចក្លាយជាអ្នកនាំមុខគេ នៅលើទីផ្សារនៃការអភិវឌ្ឍន៍ web ។

# មេរៀនទី ២

## Building Block

**1.អថេរ (Variables)**

Variableគឺជាគ្រឹះដ៏សំខាន់សំរាប់ភាសាកុំព្យូទ័រវាត្រូវបានគេប្រើដើម្បីផ្ទុកនូវតំលៃជាបណ្តោះអាសន្ននៅពេលដែលប្រតិបត្តិការ script ម្តងៗ ។ variable ត្រូវបានផ្តល់តំលៃទៅអោយ នៅពេលដែល Script ចាប់ផ្តើមតំណើរការ ឬ នៅពេលអ្នកប្រើប្រាស់បញ្ចូល ឬបានមកពីការចាប់យកទិន្នន័យពី Databaseអ្នកអាចប្រើប្រាស់ variable គ្រប់ពេលទាំងអស់ នៅពេលដែល script ចាប់ផ្តើមតំណើរការជាមួយទិន្នន័យ ហើយអ្នកអាចកែប្រែ តំលៃដែល Variable នោះផ្ទុកពីការប្រតិបត្តិការ script មួយទៅកាន់ការប្រតិបត្តិការរបស់ script មួយផ្សេងទៀត រហូតដល់ពេលដែល script របស់អ្នកត្រូវបានបញ្ចប់ ។

សំរាប់ភាសា PHP ឈ្មោះរបស់ variable ត្រូវតែចាប់ផ្តើមដោយនិមិត្តសញ្ញា $ (dollar sign)អ្នកអាចផ្តល់នូវឈ្មោះរបស់ variable ជាតួអក្សរ តំលៃលេខ ឬ underscore ( _ ) ក៏ប៉ុន្តែអ្នកមិនអាចប្រើអក្សរដកឃ្លាជាមួយឈ្មោះរបស់ variable នោះទេ ។

ឧទាហរណ៍ ខាងក្រោមគឺជាការផ្តល់ឈ្មោះទៅអោយ variable ដែលត្រឹមត្រូវ :

```
$sok ;
$sok_som_neang ;
$_Dara ;
$Chenda22 ;
```

ឧទាហរណ៍ ការផ្តល់ឈ្មោះទៅអោយ variable ដែល**មិនត្រឹមត្រូវ** :

```
$123 ;
$*ABC ;
$A+B ;
```

Variable របស់ PHP អាចផ្ទុកនូវប្រភេទទិន្នន័យដែលជាតំលៃលេខ តួអក្សរ object , arrayBooleans ហើយរាល់ចំនុះរបស់ variable អាចធ្វើការផ្លាស់ប្តូរគ្រប់ពេលវេលា ។ ជាទូទៅការប្រកាសVariable ឬ ការផ្តល់តំលៃទៅអោយ variable អ្នកអាចអនុវត្តន៏នូវ statement ដូចខាងក្រោម ។

```
$num1 = 5;
$num2 = 8;
```

ការប្រកាស variable ពីរ ខាងលើអ្នកបានប្រើប្រាស់នូវ assignment operator (=) ដែលនឹងរៀបរាប់លំអិតនៅក្នុងមេរៀន “ Operator and Expression “ ។បន្ទាប់ពីអ្នកបានផ្តល់នូវតំលៃទៅ variableរួចរាល់ហើយ អ្នកអាចយកវាមក ប្រើប្រាស់បាន ដូចខាងក្រោម :

print $num2; វាមានតំលៃស្មើនឹងការប្រើ print 8; ដូចច្នេះមានន័យថា $num2 ផ្ទុកតំម្លៃ ៨ ចូរចងចាំថារាល់ចុងបញ្ចប់នៃរបាយការណ៏របស់ PHP និមួយៗត្រូវតែបញ្ចប់ដោយសញ្ញា ( ; ) semicolon ។

**2 Data Types**

ប្រភេទខុសៗគ្នានៃទិន្នន័យត្រូវបានប្រើប្រាស់នូវចំនួនសរុបរបស់អង្គចងចាំផ្សេងៗគ្នា ហើយវាអាចប្រព្រឹត្តទៅនៅពេលអ្នករៀបចំវានៅក្នុង script របស់អ្នក ។ មានភាសាកម្មវិធីមួយចំនួនទាមទារអោយអ្នកសរសេរកម្មវិធី ប្រកាសនូវប្រភេទ នៃទិន្នន័យ

ពីមុខ variable ដោយឡែកសំរាប់ភាសា PHP ការប្រើប្រាស់ variable គឺមានភាពងាយស្រួល ដោយវានឹងធ្វើការគណនានូវប្រភេទទិន្នន័យដោយស្វ័យប្រវត្តិនៅពេលដែលអ្នកបានផ្តល់តំលៃទៅអោយវា ។

| **Standard Data Types** | | |
|---|---|---|
| **ប្រភេទ** | **ឧទាហរណ៍** | **ពិពណ៌នា** |
| Integer | `5` | ផ្ទុកនូវតំលៃលេខជាចំនួនគត់ |
| Double | `3.234` | ផ្ទុកនូវតំលៃលេខជាចំនួនទសភាគ |
| String | `"hello"` | ផ្ទុកនូវតំលៃជាបន្ទុំនៃតួអក្សរ |
| Boolean | `True` | ផ្ទុកនូវតំលៃពិសេសគឺ true ឬ false |
| Array | | មេរៀនទី |
| Object | | មេរៀនទី |

ឧទាហរណ៍ ១

**<u>Gettype.php</u>**

```
<html>
<head><titile>Display Data Type</title>
</head>
<body>

<h2>Using gettype</h2>

<?php
$testing;
Print gettype($testing);// NULL
$testing = 5;
print gettype($testing); // integer
print "<br />";
$testing = "five";
print gettype($testing); // string
print "<br />";
$testing = 5.0;
print gettype($testing); // double
print "<br />";
$testing = true;
print gettype($testing); // boolean
print "<br />";
?>
```

```
25:
26:     </body>
27:     </html>
```

នៅពេលដែល variable $testing ត្រូវបានប្រកាសនៅបន្ទាត់ទី ០៩ ដោយមិនបានផ្តល់តំលៃទៅអោយវា ដូចច្នេះនៅពេលដែលប្រើប្រាស់ gettype() function ដើម្បីត្រួតពិនិត្យ variable នៅបន្ទាត់ទី១០ នោះអ្នកនឹង ទទួលបាននូវ លទ្ធផលជាអក្សរ Null ។ បន្ទាប់ពីនេះ variable $testing ត្រូវបានផ្តល់នូវតំលៃជាតួលេខនៅបន្ទាត់ទី ១១ គឺលេខ ៥ ដែលជាចំនួនគត់ ឬ អ្នកអាចនិយាយបានថាតំលៃលេខដែលគ្មានក្បៀសដូច្នេះលទ្ធផលដែលនឹងទទួលបានបន្ទាប់ពីការប្រើប្រាស់នូវ gettype() function បន្ទាត់ទី១២ គឺ // integerចំណែកការផ្តល់នូវតំលៃ "five" ទៅអោយ variable $testing នៅបន្ទាត់ទី ១៥ គឺជាបន្តុំនៃតួអក្សរ ។នៅពេលដែលអ្នកចង់ធ្វើការជាមួយតំលៃជា string អ្នកត្រូវតែដាក់តំលៃនោះស្ថិតនៅក្នុងចន្លោះ សញ្ញា ( “ ) Double quotation mark ឬ ( ‘ ) single quotation mark ។

តំលៃជាប្រភេទ double ត្រូវបានផ្តល់ទៅអោយ variable $testing ដែលស្ថិតនៅបន្ទាត់ទី ១៨ជាតំលៃលេខ 5.0 ដែលតំលៃនេះជាតំលៃលេខទសភាគ ឬ ជាតំលៃលេខដែលមានក្បៀស។ តំលៃជាប្រភេទ Boolean ត្រូវបានផ្តល់ទៅអោយ variable $testing នៅបន្ទាត់ទី ២១ ហើយតំលៃនេះអាចមានតែពីរប៉ុណ្ណោះគឺ true ឬ false ។

**<u>សំគាល់</u> :**

*ភាពខុសគ្នារវាងការប្រើប្រាស់នូវ (“ ) double quotation mark និង ( ‘ ) single quotation mark*

Double quotation mark អនុញ្ញាតិអោយយើងប្រើប្រាស់នូវ variable បញ្ចូលជាមួយ ពីព្រោះ PHP engine នឹងជំនួសនូវតំលៃដែលជា variable ។ សូមពិនិត្យមើលឧទាហរណ៍ខាងក្រោម-

```
$name = "Rithya"; .
print "hello, $name"; // hello,Rithya .
```

ប្រសិនបើអ្នកប្រើប្រាស់នូវ single quotation mark variable មិនត្រូវបានជំនួសដោយតំលៃនោះទេ ។

```
print 'hello, $name'; // hello, $name .
```

ឧទាហរណ៍ ២

**<u>Quotation.php</u>**

```
<html>
<head><title>Single Quotation and Double Quotation mark</title>
</head>
<body>
<h2> Using double quatation and Signle quatation mark</h2>

<?
$name = "Rithya";
print "Hello,$name<br/>"; // Hello,Rithya
print 'Hello,$name';  // Hello,$name
?>

</body>
</html>
```

### 3.Displaying Type Information with `var_dump()`

`gettype()` គឺជា `function` ដែលប្រើដើម្បីទទួលនូវប្រភេទ `variable` ដោយឡែក `var_dump()` ប្រើដើម្បីប្រាប់នូវប្រភេទ `variable` និង ចំនុះរបស់វា ។ ច្រើនជាងនេះទៅទៀត សំរាប់ប្រភេទតំលៃដែលស្មុគស្មាញដូចជា `arrays` និង `object` `var_dump()` ផ្តល់អោយនូវពតិមានគ្រប់ប្រភេទដែលមាននៅក្នុង`Variable` នោះ ។

ឧទាហរណ៍ ៣

**Var_dump.php**

```
<html>
<head>
<title>Displaying Type Information with var_dump</title>
</head>
<body>
<h2>using Var_dump</h2>

<?php
$testing=5;
print var_dump($testing);
?>

</body>
</html>
```

### 4.The Cast Operators

PHPផ្តល់អោយនូវវិធីដើម្បធ្វើការផ្លាស់ប្តូរនូវប្រភេទទិន្នន័យដោយប្រើប្រាស់**castoperators** ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម:

| **Operator** | **Changes Type To** |
|---|---|
| (int), (integer) | Integer |
| (float), (real), (double) | Floating point |
| (string) | String |
| (bool), (Boolean) | Boolean |
| (array) | Array |
| (object) | Object |

ឧទាហរណ៍ ៥

**Casting.php**

```
<html>
<head>
        <title>Casting variable</title>
</head>
<body>
<h2>Using Casting to Changing Type</h2>
<?php
        $unexpect=3.14;
```

```
        $holder = (double)$unexpect;
        print gettype($holder);
        print "--- $holder<br/>";

        $holder = (string)$unexpect;
        print Gettype($holder);
        print "-- $holder<br/>";

        $holder = (integer)$unexpect;
        print gettype($holder);
        print "-- $holder<br/>";

        $holder = (Double)$unexpect;
        print  gettype($holder);
        print   "---- $holder<br/>";

        $holder = (boolean)$unexpect;
        print gettype($holder);
        print "-- $holder<br/>";

    ?>
</body>
</html>
```

**5.Operators and Expressions**

Operators គឺជានិមិត្តសញ្ញាទាំងឡាយណាដែលអ្នកអាចប្រើតំលៃមួយ ឬ ច្រើន បង្កើតចេញជាតំលៃថ្មីមួយទៀត ហើយតំលៃដែលប្រតិបត្តិដោយ operator នោះត្រូវបានគេហៅថា operand ។

Operand គឺជាតំលៃដែលចូលរួមជាមួយ operator ដែលជាទូទៅ មាន operand ពីរជាមួយOperator មួយ ។

ឧទាហរណ៍ការប្រើ operand ពីរ ជាមួយ operator ដើម្បីបង្កើតចេញជាតំលៃថ្មីមួយផ្សេងទៀត។

4 + 5 .

៤ ហើយនិង ៥ គឺជា operand ដែលត្រូវបាន operated ដោយ addition operator (+) ដើម្បីបង្កើតនូវតំលៃថ្មី គឺ ៩ ។ ការផ្គុំនូវ operand និង operator ដើម្បីបង្កើតជាលទ្ធផល ត្រូវបានគេហៅថា expression

**5.1 The Assignment Operator**

**Assignment operators** ប្រើដើម្បីផ្តល់នូវតំលៃទៅអោយ variable ។ ដូចដែលអ្នកបានជួបខាងលើ assignment operator ត្រូវបាន initialize variable គ្រប់ពេល វាគឺជាអក្សរ ( = ) ។Assignment operator ចាប់យកតំលៃពី operand ខាងស្តាំទៅអោយ operand ខាងឆ្វេងដូចឧទាហរណ៍

ខាងក្រោម :

```
$name = " DYCHANDOEUN " ;
Print $name;  .
```

ជាទូទៅខាងឆ្វេងនៃ Assignment operator ច្រើនតែជា variable ។

## 5.2 Arithmetic Operators

| **Arithmetic Operators** | | | |
|---|---|---|---|
| **Operator** | **Name** | **Example** | **Result** |
| + | បូក ( Addition ) | 10+5 | 15 |
| / | ចែក ( Division ) | 10/3 | 3.333333333333 |
| * | គុណ ( Multiplication ) | 10*5 | 50 |
| % | យកសំណល់ពីផលចែក ( Modulus ) | 10%3 | 1 |
| - | ដក ( Subtraction ) | 10-2 | 2 |

## 5.3 The Concatenation Operator ( . )

**Concatenation operator** ប្រើដើម្បីភ្ជាប់ string សំរាប់ operator មួយនេះវាធ្វើការជាមួយតែ string ប៉ុណ្ណោះ ។ ដូច្នេះរាល់ operand ដែលមិនមែនជា string វានឹង convert អោយទៅជា string សូមពិនិត្យមើលឧទាហរណ៍ :

`"hello"." world"` ការសរសេរបែបនេះវាស្មើនឹងការសរសេរ `"hello world"` ។

$year = 2007; .

Print "Happy khmer new year_".$year ;

Variable $year ដែលជាប្រភេទ integer ត្រូវបានបំលែងទៅជា string " 2007 " មុនពេលដែលវាត្រូវបានភ្ជាប់ជាមួយ string " Happy khmer new year " ។

## 5.4 Combined Assignment Operators

```
$x = 4;
$x = $x + 4; // លទ្ធផល $x គឺ 8
```

ឬ អ្នកអាចជំនួសដោយការសរសេរដូចខាងក្រោម

```
$x = 4;
$x += 4; // $ លទ្ធផល $x គឺ 8
```

| ***Some Combined Assignment Operators*** | | |
|---|---|---|
| **Operator** | **Example** | **Equivalent to** |
| += | $x += 5 | $x = $x + 5 |
| -= | $x -= 5 | $x = $x - 5 |
| /= | $x /= 5 | $x = $x / 5 |
| *= | $x *= 5 | $x = $x * 5 |

| ***Some Combined Assignment Operators*** | | |
|---|---|---|
| **Operator** | **Example** | **Equivalent to** |
| `%=` | `$x %= 5` | `$x = $x % 5` |
| `.=` | `$x .= " test"` | `$x = $x." test"` |

## 5.5 Comparison Operators

Comparison operators ប្រើដើម្បីប្រៀបធៀបនូវ operands ទាំងឡាយ ដោយផ្តល់នូវតំលៃត្រលប់ជា Boolean ( true or false ) ។

ឧទាហរណ៍ដើម្បីត្រួតពិនិត្យតំលៃដែលមាននៅក្នុង $x និងជាតំលៃដែលតូចជាងប្រាំ អ្នកអាចប្រើជាមួយនឹង less than operator ។

```
$x < 5
```

ប្រសិនបើ $x ផ្ទុកតំលៃ លេខ 4 expression ខាងលើនឹងផ្តល់ជាតំលៃ true ប៉ុន្តែប្រសិនបើ $x ផ្ទុកតំលៃជាលេខ 7 នោះ expression នឹងផ្តល់នូវតំលៃ false ។

| **Comparison Operators** | | | |
|---|---|---|---|
| **Operator** | **ឈ្មោះ** | **ផ្តល់តំលៃ True ប្រសិនបើ** | **($x គឺ 4)** |
| `==` | សមមូល | តំលៃខាងឆ្វេង ស្មើ តំលៃខាង ស្តាំ | `$x == 5` |
| `!=` | Non-equivalence | តំលៃខាងឆ្វេង ខុសពី តំលៃខាងស្តាំ | `$x != 5` |
| `= = =` | Identical | តំលៃខាងឆ្វេង ស្មើ តំលៃខាងស្តាំ ហើយ តំលៃទាំងពីរត្រូវតែមានប្រភេទដូចគ្នា | `$x===5` |
| `>` | ធំជាង | តំលៃខាងឆ្វេងធំជាង តំលៃខាងស្តាំ | `$x > 4` |
| `>=` | ធំជាង ឬ ស្មើ | តំលៃខាងឆ្វេងធំជាង ឬ ស្មើ តំលៃខាងស្តាំ | `$x >= 4` |
| `<` | តូចជាង | តំលៃខាងឆ្វេងតូចជាង តំលៃខាងស្តាំ | `$x < 4` |
| `<=` | តូចជាង ឬ ស្មើ | តំលៃខាងឆ្វេងតូចជាង ឬ ស្មើតំលៃខាងស្តាំ | `$x <= 4` |

Operator ខាងលើនេះភាគច្រើនប្រើជាមួយ integers or double ហើយសំរាប់ operator( == ) គឺប្រើដើម្បីប្រៀបធៀបតំលៃដែលជា strings ។

## 5.6 Logical Operators

| Logical Operators | | | | |
|---|---|---|---|---|
| **Operator** | **Name** | **Returns True if...** | **Example** | **Result** |
| `||` | Or | Left or right is true | `true || false` | `True` |
| `Or` | Or | Left or right is true | `true || false` | `true` |
| `Xor` | Xor | Left or right is true but not both | `true xor true` | `false` |
| `&&` | And | Left and right are true | `true && false` | `false` |
| `And` | And | Left and right are true | `true && false` | `false` |
| `!` | Not | The single operand is not true | `! true` | `false` |

**Logical operators** បំលែង operand អោយទៅជាតំលៃ Boolean រួចធ្វើការប្រៀបធៀបតំលៃទាំងនោះ ។

`Or` operator ឬ ( || ) ផ្តល់តំលៃ true ប្រសិនបើ operand ខាងឆ្វេង ឬ ខាងស្តាំណាមួយមានតំលៃ true ។

ឧទាហរណ៍ ១. true || false លទ្ធផលគឺ true ។`And` operator ឬ ( && ) ផ្តល់តំលៃ true នៅពេលដែល operand ទាំងពីរមានតំលៃ true ។

ឧទាហរណ៍ ២. true && false លទ្ធផលគឺ false ។

ឧទាហរណ៍ ៣. ( $x > 2 ) && ( $x < 15 )

## 5.7 Increment/Decrement Operators

**Increment/decrement operators** ប្រើដើម្បីបង្កើន ឬ បន្ថយតំលៃ របស់ variable ដែលជា Integer ហើយជាទូទៅប្រើដើម្បីរាប់ Iteration របស់ loop ។

$x = $x + 1; // $x is incremented.

$x += 1; // $x is incremented.

$x++; // $x is incremented

. $x = $x - 1; // $x is decremented.

$x--; // $x is decremented.

$x- = 1; // $x is decremented.

| **Operator** | **Name** | **Effect on $var** | **Value of the Expression** |
|---|---|---|---|
| $var++ | Post-increment | $var is incremented by 1 | The previous value of $var |
| ++$var | Pre-increment | $var is incremented by 1 | The new value of $var (incremented by 1). |
| $var-- | Post-decrement | $var is decremented by 1 | The previous value of $var |
| --$var | Pre-decrement | $var is decremented by 1 | The new value of $var (decremented by 1). |

ឧទាហរណ៍

$num1 = 5;

$num2 = $num1++; // post-increment, $num2 ត្រូវបានផ្តល់នូវតំលៃដើមរបស់ $num1

print $num1; // លទ្ធផលដែលនឹងត្រូវបង្ហាញគឺ តំលៃរបស់ $num1 គឺ ៦

print $num2; // លទ្ធផលដែលនឹងត្រូវបង្ហាញគឺ ជាតំលៃដើមរបស់ $num1 គឺ ៥

ឧទាហរណ៍ :

$num1 = 5;

$num2 = ++$num1; // pre-increment, $num2 ត្រូវបានផ្តល់នូវតំលៃថ្មីរបស់ $num1

ទៅអោយ $num2 ។

print $num1; // លទ្ធផលដែលនឹងត្រូវបង្ហាញគឺ តំលៃរបស់ $num1 គឺ ៦

print $num2; // លទ្ធផលដែលនឹងត្រូវបង្ហាញគឺ ជាតំលៃរបស់ $num1 គឺ ៦

## 6.Constants

ជាទូទៅ Variables ត្រូវបានគេប្រើដើម្បីផ្ទុកនូវតំលៃ ពីព្រោះតំលៃ និង ប្រភេទរបស់វាអាច នឹងត្រូវផ្លាស់ប្តូរបានគ្រប់ពេលវេលា ។ ប្រសិនបើអ្នកចង់ធ្វើការជាមួយតំលៃដែលមិនប្រែប្រួលនៅក្នុងការ ប្រតិបត្តិការកូដរបស់អ្នក អ្នកអាចប្រើប្រាស់នូវ constant ។ PHP បានផ្តល់នូវ define() function ដើម្បី បង្កើតនូវ constant ។

```
define("CONSTANT_NAME", 42);
```

តំលៃដែលអ្នកអាចផ្តល់ទៅអោយ constant គឺត្រូវតែជា តំលៃលេខ ឬ តួអក្សរ ហើយសំរាប់ការផ្តល់ឈ្មោះរបស់ constant អ្នកគួរតែប្រើអក្សរធំ ។ វាលការប្រើប្រាស់ constant variable អ្នកគ្រាន់យក ឈ្មោះរបស់ constant នោះមកប្រើ ប៉ុន្តែមិនមានសញ្ញា ($) dollar symbol នៅពីមុខនោះទេ ។

ឧទាហរណ៍ ៦

**constant.php**

```
01:  <html>
02:  <head>
03:  <title>Defining a constant</title>
04:  </head>
05:  <body>
06:  <div>
07:
08:  <?php
09:  define("USER", "Ankor");
10:  print "Welcome ".USER;
11:  ?>
12:
13:  </div>
14:  </body>
15:  </html>
```

នៅបន្ទាត់ទី ១០ យើងបានប្រើ concatenation operator ដើម្បីភ្ជាប់តំលៃរបស់ constant និង អក្សរ "Welcome" ពីព្រោះ PHP engine មិនមានវិធីសាស្ត្រដើម្បីបែងចែក រវាង constant និង string ដែលនៅក្នុង quotation mark នោះទេ ។

ជា Default constant គឺ case sensitive ប៉ុន្តែអ្នកអាចផ្លាស់ប្តូរដោយទទួលយកនូវ argument ទី៣ ជា boolean មកប្រើក្នុង define() function ដើម្បីកំណត់អោយការប្រើប្រាស់ឈ្មោះ constant ជា Case insensitive ដូចមានក្នុងឧទហរណ៍ខាងក្រោម ។

```
define("USER", "Ankor", true); .
```

ដូច្នេះអ្នកអាចប្រើប្រាស់ constant ដោយមិនមានការខ្វាយខ្វល់អំពីអក្សរតូចឬធំឡើយ ។

```
print User;
print usEr;
print USER;
```

ឧទាហរណ៍ ៧

**constant2.php**

```
<html>
<head>
<title>Defining a constant</title>
</head>
```

```
<body>
<div>

<?php
        define ("USER", "Angkor",true);
        print "Welcome".uSER."<br/>";
        print "Welcome".uSeR."<br/>";
        print "Welcome".usEr."<br/>";
        print "Welcome".uSER."<br/>";
?>

</div>
</body>
</html>
```

# មេរៀនទី ៣ Going With The Flow

## 1. The if Statement

If statement គឺជាវិធីសាស្ត្រដែលប្រើដើម្បីត្រួតពិនិត្យទៅលើការប្រតិបត្តិការរបស់ statement ដែលនៅបន្ទាប់វា ( អាចជា single statement ឬ ជា block of code ដែលឋិតនូវក្នុងសញ្ញា {-------} )

If statement ធ្វើការវាយតម្លៃ expression ដែលនៅក្នុងសញ្ញា (---) ប្រសិនបើ expression របស់ ifផ្តល់តំលៃ true នោះ statement ដែលនៅខាងក្រោមនឹងត្រូវអនុវត្តន៏ ។

កូដខាងក្រោមបង្ហាញពី ទំរង់នៃ if statement ដែលត្រួតពិនិត្យ expression ជា string ។

```
if(expression)
{
  // code ដែលនឹងត្រូវអនុវត្តន៏នៅពេលដែល expression ផ្តល់តំលៃ true
}
```

ឧទាហរណ៏ ៨

```
<Html>
<head>
<title> Using if Statement </title>
</head>
<body>
<h2>Using if statement</h2>
<?php

$user="Thanith";
$pwd="123";
If(($user=  ="Thanith" && pwd=  ="123"))
print   "Login successful";
else
print "Login fail !";

?>
</body>
</Html>
```

ការប្រើប្រាស់ comparasion operator (==) ដើម្បីប្រៀបធៀប variable $user និង តំលៃជាអក្សរ " Thanith " variable $pwd ជាមួយនឹងតំលៃ "123" ប្រសិនបើតំលៃដែលត្រូវប្រៀបធៀបនិងតំលៃរបស់ variable ដូចគ្នានោះ expression នឹងផ្តល់តំលៃ true ហើយ code block នឹងត្រូវអនុវត្តន៏ប៉ុន្តែប្រសិនបើតំលៃរបស់ $user ប្តូរទៅជា "Romchong" ឬ តំលៃរបស់ $pwd ប្តូរទៅជា "124" ហើយតំណើរការ scriptឡើងវិញ នោះ expression ដែលនៅក្នុង if statement នឹងផ្តល់តំលៃ falseហើយCode block នឹងមិនត្រូវអនុវត្តន៏ ដែល script នឹងបែរទៅអនុវត្តន៏នូវ else statement ជំនួសវិញ ។

```
else
print "Login fail !";
```

### 1.1 Using the `else if` Clause with the `if` Statement

អ្នកអាចប្រើប្រាស់នូវទំរង់ if/else ឬ else/if ដើម្បីធ្វើការពិនិត្យលើ expression មុនពេលដែល Script របស់អ្នកត្រូវអនុវត្តន៍ នូវ default block of code ។

```
if ( expression )
{
// code ដែលត្រូវអនុវត្តន៍ ប្រសិនបើ expression ផ្តល់តម្លៃ true
}
else if ( another expression )
{
// code ដែលត្រូវអនុវត្តន៍ ប្រសិនបើ expression ដំបូងផ្តល់តម្លៃ false
// ហើយ expression របស់វា true
}
else
{
// code ដែលត្រូវអនុវត្តន៍ ប្រសិនបើពុំមាន expression ណាមួយ true
}
```

ប្រសិនបើ expression ដំបូងមិនផ្តល់នូវតំលៃ true នោះ block of code ដំបូងក៏មិនត្រូវបាន អនុវត្តន៍ដែរ else if ចាប់ផ្តើមធ្វើការជាមួយ expression របស់ខ្លួន ប្រសិនបើ expression នេះផ្តល់តំម្លៃ True នោះ block កូដទី២ នឹងត្រូវអនុវត្តន៍ ផ្ទុយមកវិញកូដដែលស្ថិតនៅក្នុង else clauseនឹងត្រូវអនុវត្តន៍ ជំនួសវិញ ។ អ្នកអាចប្រើប្រាស់ else if បានជាច្រើនទៅ តាមការចង់បានរបស់អ្នក ហើយប្រសិនបើ អ្នកមិន ចង់អោយមាន Default action ទេ អ្នកមិនចាំបាច់ប្រើប្រាស់ else clause នោះទេ ។

## 2. The switch Statement

switch statement គឺជាវិធីសាស្រ្តដែលប្រើដើម្បីផ្លាស់ប្តូរលំដាប់នៃការអនុវត្តន៍កូដរបស់កម្មវិធីដែលអាស្រ័យទៅលើការវាយតំលៃរបស់ expression ។ ការប្រើប្រាស់ if statement ជាមួយ else if អ្នកអាចប្រើប្រាស់ expressionបានច្រើន ដោយឡែក switch ប្រើប្រាស់តែ expression មួយប៉ុណ្ណោះ ។ការអនុវត្តន៍ code ខុសៗគ្នាគឺអាស្រ័យទៅលើលទ្ធផលនៃexpression ដែលផ្តល់តំលៃជា simple typeដូចជា ( number , string , Boolean…… ។ ល ។ ) ។

```
switch (expression)
{
  case exp:
    // execute this if expression results in result1
    break;
  case exp:
    // execute this if expression results in result2
    break;
```

```
default:
        // កូដនឹងត្រូវអនុវត្តន៍ប្រសិនបើមិនមាន expression ណាដូចនឹង expression របស់ case
}
```

Expression របស់ switch statement ជាទូទៅត្រូវបានប្រើជា variable ហើយ codeរបស់ switch statement ត្រូវសរសេរនៅក្នុង case statement ។ រាល់តំលៃ expression របស់ caseនិមួយៗ ត្រូវបានយកមកផ្ទៀងផ្ទាត់ជាមួយ expression របស់ switch statement ប្រសិនណាតំលៃរបស់case ណាមួយដូចនឹង expression របស់ switch statement នោះ code block នឹងត្រូវអនុវត្តន៍ បន្ទាប់ មក break statement នឹងបញ្ចប់ការអនុវត្តន៍ switch statement ប៉ុន្តែប្រសិនបើពុំមាន case expression ណាមួយ ដូចនឹង switch expression នោះ default statement គឺជាអ្នកអនុវត្តន៍ ។

**ឧទាហរណ៍ ៩**

```
<Html>
<head>
<title>
Using switch Statement
</title>
</head>
<body>
<h2>Using switch statement</h2>

<?php

$name="Daro";
switch($name)
{
        case "Dara":
                print " Hello Dara";
        break;

        case "Many":
                print "Hello Many";
        break;
        case "Daro":
                print "Hello Daro";
        break;

        Default:
                print "No one know";
}

?>
```

```
</body>
</Html>
```

### 3. Loops

Loop statement អាចអោយអ្នកអនុវត្តន៏នូវការងារម្តងហើយម្តងទៀតនៅក្នុង program របស់អ្នក រហូតដល់វាសំរេចលក្ខ័ណ្ឌ ឬ អ្នកបញ្ជាអោយចាកចេញពី loop ។

#### 3.1 The `while` Statement

While loops គឺជាប្រភេទមួយនៃ loops ។ expression របស់វាផ្តល់ជាតំលៃ true ឬ false ដូច្នេះប្រសិនបើ expression ផ្តល់តំលៃជាលទ្ធផល true នោះ code block នឹងត្រូវអនុវត្តន៏ ដែល blockCode ស្ថិតនៅក្នុង loop នោះ ត្រូវបានគេអោយឈ្មោះថា iteration ។

```
while ( expression )
{
   // do something
}
```

ឧទាហរណ៏ ១០

**while.php**

```
<html>
<head><title>The While Statement</title>
</head>
<body>
<h2>Using the While Statement</h2>

<?php

$sum=0;$i=1;
$str="";
While ($i<=10)
{
		$sum+=$i;
		$str= $str."$i+";
	$i++;
}
		echo substr($str,0,-1)."=$sum";

?>

</body>
</html>
```

#### 3.2 The do...while Statement

**`do..while` statement** វាមានលក្ខណៈប្រហាក់ប្រហែលនឹង while statement ប៉ុន្តែលក្ខណៈពីរដែលខុសគ្នាពី while statement គឺ block code របស់ do while statement អនុវត្តន៏មុនពេលដែល Expression របស់វាត្រូវបាន test និង ផ្តល់តំលៃ true ឬ false ។

```
do
{
………………………
 // code to be executed
………………………
}
while (expression);
```

Test expression នៃ `do...while` statement ត្រូវតែបញ្ចប់ដោយ ( ; ) semicolon.

ឧទាហរណ៍ ១១

**`dowhile.php`**

```
<html>
<head><title>The Do While Loop Statement</title>
</head>
<body>
<h2>Using the do while Statement</h2>
</body>
</html>
<?php
$sum=0;$i=1;$str="";
Do
{
	$sum=$sum+$i;
	$str= $str."$i+";
	$i=$i+1;
}
While ($i<=10);
{
  $i=$i-1;
  echo substr($str,0,-1)."=$sum";

}
?>
```

### 3.3 The `for` Statement

```
for ( initialization expression; test expression; modification expression )
{
  // code to be executed
}
```

រាល់ expression និមួយៗដែលមាននៅក្នុងសញ្ញាវង់ក្រចករបស់ for statement គឺត្រូវបែងចែកគ្នាដោយ semicolon ( ; ) ។ expression ទីមួយ ចាប់ផ្តើមរាប់ variable ហើយ expression ទី២ធ្វើការត្រួតពិនិត្យលក្ខ័ណរបស់ for loop និង expression ទី៣ បង្កើន ឬ បន្ថយនូវចំនួនការរាប់ ។

ឧទាហរណ៍ ១២

**forloop.php**

```
<html>
<head>
<title>The for Statement</title>
</head>
<body>
```

```
<h2>Using for Statement</h2>

<?php
$sum=0;$str="";
for ($i=1; $i<=10; $i++ )
{
$sum+=$i;
$str= $str."$i+";
}
echo substr($str,0,-1)."=$sum";
 ?>

</body>
</html>
```

នៅពេលដែល program តំណើរការដល់ for loop variable $i ត្រូវបាន initialize ហើយTest expression ចាប់ផ្តើមត្រួតពិនិត្យទៅលើ expression របស់ខ្លួន ប្រសិនបើ expression ផ្តល់តំលៃTrue នោះ code block នឹងត្រូវអនុវត្តន៍ បន្ទាប់មក $i variable ធ្វើការបង្កើនតំលៃមួយហើយ testExpression ចាប់ផ្តើមធ្វើការត្រួតពិនិត្យទៅលើ expression របស់ខ្លួនសារជាថ្មីម្តងទៀត ។ ប្រតិបត្តិការនេះបន្តការអនុវត្តន៏រហូតដល់ test expression ផ្តល់តំលៃ false ។

### 3.4 Breaking Out of Loops with the `break` Statement

រាល់ loop statement គឺសុទ្ធតែមានភ្ជាប់មកជាមួយនូវ test expression ដែលអាចអោយអ្នក បញ្ឈប់វាបាន ឬ ដោយប្រើប្រាស់ break statement ។

ឧទាហរណ៏ ១៣

**break.php**

```
<html>
<head>
<title>the break Statement</title>
</head>
<body>
<div>

<?php

$counter = -5;
for ( ; $counter <= 10; $counter++ ) {
  if ( $counter == 0 ) {
  break;
  }
  $temp = 2000/$counter;
  print "2000 divided by $counter is.. $temp<br />";
  }
?>

```

```
20: </div>
21: </body>
22: </html>
```

យើងបានប្រើប្រាស់នូវ if statement នៅបន្ទាត់ទី ១៣ ដើម្បីត្រួតពិនិត្យនូវតំលៃរបស់ variable$counter ប្រសិនបើតំលៃរបស់វាស្មើនឹងសូន្យ 0 break statement នឹងត្រូវអនុវត្តន៍ ដែលត្រូវចាកចេញពីBlock code របស់ for loop statement ហើយអនុវត្តន៍នូវ statement ដែលនៅបន្ទាប់ពី for statement ។

### 3.5 Skipping an Iteration with the `continue` Statement

`Continue` statement បញ្ឈប់តំណើរការរបស់ iteration ដែលកំពុងអនុវត្តន៍ ប៉ុន្តែមិនបញ្ឈប់ តំណើរការរបស់ loop ទាំងស្រុងនោះទេ វានឹងបន្តធ្វើការជាមួយ iteration ក្រោយៗបន្តទៀត រហូតដល់ Expression ផ្តល់តំលៃ false ឬ ជួប នឹង break statement ។

**ឧទាហរណ៍ ១៤ continue.php**

```
01: <!
02: exam continue statement
03: >
04:         <html>
05:         <head>
06:         <title>Using the continue Statement</title>
07:         </head>
08:         <body>
09:         <div>
10:
11:         <?php
12:
13:         $counter = -5;
14:         for( ; $counter <= 10; $counter++ )
15:         {
16:                 if ( $counter == 0 )
17:                 {
18:                 continue;
19:                 }
20:         $temp = 2000/$counter;
21:         print "2000 divided by $counter is .. $temp<br />";
22:         }
23:
24:         ?>
25:
26:         </div>
27:         </body>
28:         </html>
```

នៅបន្ទាត់ទី១៤យើងបានជំនួស break statement ដោយការប្រើប្រាស់ continue statement ប្រសិនបើ `variable $counter` ស្មើ 0 `iteration` នឹងត្រូវរំលងការអនុវត្តន៍ ហើយបន្តអនុវត្តន៍ `iteration` ជាបន្តទៀត ។

## 3.6 Nesting Loops

ឧទាហរណ៍ ១៥:

**nestingLoop.php**

```
<html>
<head><title>using nested loop</title>
</head>
<body>
<h2>Using nested loop</h2>

<?php

$j=0;$i=0;
for($i=0;$i<=5;$i++)
{
        print "The Value  i=".$i."<br/>";
        for($j=0;$j<=3;$j++)
        {
        print "value J=".$j."<br/>";
        }
}

?>

</body>
</html>
```

ការប្រើប្រាស់ for statement ដើម្បី បង្ហាញ table ទៅកាន់ brower ។

### *Nesting Two `for` Loops*

```
 <!
Nesting loops
>
<html>
<head>
```

```
<title>Nesting Two for Loops</title>
</head>
<body>
<div>

 <?php

print "<table border=\"1\">\n";
for ( $y=1; $y<=12; $y++ )
{
 print "<tr>\n";
        for ( $x=1; $x<=12; $x++ )
        {
        print "\t<td>";
        print ($x*$y);
        print "</td>\n";
        }
print "</tr>\n";
}
print "</table>";

 ?>

</div>

</body>
</html>
```

# មេរៀនទី ៤

# Function

## 1.What is Functions ?

Function គឺជាបន្ទុំនៃ block code ដែលអ្នកបង្កើត ហើយអនុញ្ញាតិអោយអ្នកហៅ យកមកប្រើ នៅក្នុង script របស់អ្នក ។ នៅពេលដែលអ្នកហៅ function កូដ ដែលនៅខាងក្នុងនឹងត្រូវអនុវត្តន៍ ហើយអ្នកក៏អាច បញ្ជូនតំលៃទៅអោយ function ឬ ទទួលតំលៃពី function មកវិញ ។

### 1.1 Calling Functions

Function មានពីរប្រភេទគឺ Function ដែលមានស្រាប់ ភ្ជាប់មកជាមួយនឹងភាសាកម្មវិធី និងFunction ដែលអ្នកបង្កើតឡើងដោយខ្លួនឯង ។ នៅក្នុងភាសា PHP មាន built-in function ជាច្រើនដែលផ្តល់នូវភាពងាយស្រួលសំរាប់ការសរសេរកូដរបស់អ្នក ។

### 1.2 Defining a Function

អ្នកអាចបង្កើត function ដោយប្រើ function statement function function_name( $argument1, $argument2 )

```
{
  //
}
```

ប្រសិនបើ function របស់អ្នកតំរូវអោយមាន argument ចាប់ពីពីរឡើងទៅ អ្នកត្រូវតែចែកវាដោយប្រើប្រាស់សញ្ញា comma( , ) ដែលជាទូទៅ argument ទាំងនោះគឺជា variable ហើយតំលៃរបស់វានឹងត្រូវផ្តល់អោយនៅពេលដែល function ត្រូវបានហៅ ។

ឧទាហរណ៍ ១៦

**Declaring a Function**

```
<html>
<head>
<title>Declaring a Function</title>
</head>
<body>
<?php
function bigsum()
  {
      $sum=0;
      for ($i=1; $i<=10; $i++ )
      {
      $sum+=$i;
      $str= $str."$i+";
      }
      echo substr($str,0,-1)."=$sum";

  }
bigsum();
?>
</body>
```

```
</html>
```

លទ្ធផលដែលបង្ហាញនៅលើ browser គឺជា string នៃតួរអក្សរ 1+2+3+…………+10 = 55 ឧទាហរណ៏ខាងលើនេះគឺជាការបង្កើតនូវ function មួយឈ្មោះថា bigsum()ដែលជា function មិនមាននូវ Arguments នោះទេ ។សំរាប់ឧទាហរណ៏ទី ២០ យើងនឹងបង្កើត function ដែលប្រើប្រាស់ argument ។

**ឧទាហរណ៏ ២០**

```
<html>
<head>
<title>Declaring a Function</title>
</head>
<body>

<?php

function bigsum($count)
{
        $sum=0;
        for($i=1; $i<=$count; $i++ )
        {
        $sum+=$i;
        $str= $str."$i+";
        }
        echo substr($str,0,-1)."=$sum";
}

bigsum(10);

?>

</body>
</html>
```

### 1.2.1 <u>Returning Values from User-Defined Functions</u>

នៅឧទាហរណ៏ខាងលើយើងទទួលបាននូវលទ្ធផលជា string នៅលើ browser ដោយការប្រើប្រាស់ bigsum() function ។ function របស់អ្នកអាចធ្វើការផ្លាស់ប្តូរតំលៃដែលអ្នកបានផ្តល់អោយឬ មានពេលខ្លះអ្នកនឹងចង់អោយ function ផ្តល់នូវតំលៃថ្មីអោយអ្នក បន្ទាប់ពីអ្នកបានផ្តល់តំលៃទៅឱ្យវា ។

Function មួយអាចទទួលបានតំលៃដោយការប្រើប្រាស់ នូវ returnstatement ជាមួយនឹងតំលៃដែលត្រូវបញ្ជូនត្រលប់ទៅកាន់ function ។return បញ្ឈប់ប្រតិបត្តិការរបស់ function ហើយ បញ្ជូនតំលៃត្រលប់ ទៅវិញនៅពេលដែល function ត្រូវបានហៅមកប្រើ ។ខាងក្រោមគឺជាឧទាហរណ៏នៃការបង្កើត function ដែល return តំលៃពី ផលបូលចំនួនពីរតំលៃ ។

**ឧទាហរណ៏ ២១**

```
<html>
<head>
<title>A Function That Returns a Value</title>
</head>
<body>

<?php

 function addNums($num1,$num2)
{
```

```
$result = $num1 + $num2;
return $result;
}
print addNums(3,5);

?>
</body>
</html>
```

addNums() Function ត្រូវបានហៅយកមកប្រើប្រាស់ជាមួយនឹង argument ចំនួនពីរដែលជាតំលៃលេខ 3 និង លេខ 5 ដែលតំលៃទាំងនេះត្រូវបានរក្សាទុកនៅក្នុង variable $num1 និង $num2addNums function ធ្វើការគណនានូវផលបូកនៃតំលៃដែលរក្សាទុកនៅក្នុង variable ទាំងពីរហើយផ្តល់ជាលទ្ធផលទៅអោយ variable $result ។អ្នកក៏អាច `return` តំលៃដោយការហៅ `function` ដទៃទៀតបានផងដែរ `return ( another_function( $an_argument ) );`

## 2. Variable Scope

Variable ដែលប្រកាសនៅខាងក្នុង function គឺអាចប្រើប្រាស់បានតែនៅខាងក្នុង function នោះប៉ុណ្ណោះ មានន័យថាមិនអាចប្រើប្រាស់បាននៅខាងក្រៅ function ឬ នៅក្នុង function ដទៃទៀត ។

សំរាប់ project ធំៗវាអាចជួយអ្នកពីគ្រោះថ្នាក់នៃការកែប្រែតំលៃដែលមាននៅក្នុង variable ពេលដែលអ្នកប្រកាស variable ពីរ ហើយមានឈ្មោះដូចគ្នា និង ឋិតនៅក្នុង function ផ្សេងៗគ្នា ។

ខាងក្រោមគឺជាឧទហរណ៍ ស្តីពីការបង្កើត variable មួយនៅក្នុង function ហើយព្យាយាមយកVariable នោះមកបង្ហាញលើ browser ពី ក្រៅ function ។

***ចំណាំ :*** Variableដែលបង្កើតនៅខាងក្នុង function មិនអាចប្រើប្រាស់ពីខាងក្រៅ function បាននោះទេ។

**ឧទាហរណ៍ ២២:**

```
<html>
<head>
<title>Local Variable Unavailable Outside a Function</title>
</head>
<body>
<div>

<?php

function test()
{
$testvariable = "this is a test variable";
}
print "test variable: $testvariable<br/>";

?>
 </div>
</body>
</html>
```

អ្នកនឹងបានឃើញនូវលទ្ធផលនៃឧទាហរណ៍ខាងលើ ដែលតំលៃរបស់ variable $testvariable មិនត្រូវបានបង្ហាញនោះទេ ពីព្រោះពុំមាន variable ណាមួយត្រូវបានបានបង្កើតនៅខាងក្រៅ functiontest() នោះទេ ។ គួរចំណាំថា ការយក variable ដែលមិនមាន មកប្រើប្រាស់គឺមិនមានភាព error ឡើយ ។ម្យ៉ាងវិញទៀត variable ដែលប្រកាសនៅខាងក្រៅ function គឺមិនអាចយកមកប្រើក្នុង function ដោយស្វ័យប្រវត្តិនោះទេ ។

## 2.1 Accessing Variables with the `global` Statement

មានពេលខ្លះអ្នកប្រហែលជាត្រូវការប្រើប្រាស់ variable នៅក្នុង function របស់អ្នកដោយពុំតំរូវអោយមានការបញ្ជូនតំលៃតាម argument នោះទេ ។ ខាងក្រោមគឺជាឧទាហរណ៍ដែលប្រើប្រាស់នូវ global statement ដើម្បីប្រើប្រាស់នូវ variable ដែលប្រកាសខាងក្រៅ function ។

ឧទាហរណ៍ ២៣:

```
01:    <html>
02:    <head>
03:    <title>The global Statement</title>
04:    </head>
05:    <body>
06:
07:    <?php
08:
09:    $lottery=42;
10
11:    function lotteryToday()
12:    {
13:    global $lottery;
14:    print "Lottery today is $lottery<br />";
15:    }
16:
17:    lotteryToday();
18:    ?>
19:    </body>
20:    </html>
```

នៅបន្ទាត់ទី ១៣ នៃឧទាហរណ៍ទី២៣ យើងបានប្រើប្រាស់នូវ **global** ពីមុខ variable $lottery ដែលបានប្រកាសនៅក្នុង function lotteryToday() ដើម្បីសំដៅទៅកាន់ global variable $lottery ដែលបានប្រកាសនៅខាងក្រៅ function នៅបន្ទាត់ទី ០៩ ។

អ្នកត្រូវតែប្រើប្រាស់នូវ **global** statement នៅរាល់ function ដែលអ្នកចង់ប្រើប្រាស់នូវ global variable ។ អ្នកគួរប្រុងប្រយ័ត្នផងដែរនៅពេលដែលអ្នកផ្តល់តំលៃទៅអោយ variable $lottoery នៅក្នុង function ពីព្រោះ $lottery នឹងធ្វើការផ្លាស់ប្តូរតំលៃរបស់ខ្លួនទាំងអស់នៅក្នុង script របស់អ្នក ។អ្នកក៏អាចប្រកាស variable ជាមួយ **global** statement បានច្រើនក្នុងពេលតែមួយបានផងដែរ ដោយការចែកនូវ variable និមួយៗដោយសញ្ញា (,) comma ។

ឧទាហរណ៍ : **global** $var1, $var2, $var3;

# មេរៀនទី ៥ Array

## 1. What Is an Array?

អ្នកក៏បានស្គាល់រួចមកហើយអំពី variable ដែលត្រូវគេប្រើដើម្បីផ្ទុកនូវតំលៃផ្សេងៗ ។ ដោយការប្រើប្រាស់ variable អ្នកក៏អាចបង្កើតជា script អោយប្រតិបត្តិការ ឬ បង្ហាញជាពតិមានផ្សេងៗនៅរាល់ពេលដែលអ្នកតំណើរការវា ប៉ុន្តែគួរអោយសោកស្តាយ ដោយអ្នកអាច រក្សាទុកនូវតំលៃតែមួយប៉ុណ្ណោះក្នុងពេលតែមួយ និង ក្នុង variable មួយ ។

**Array** គឺជា variable ពិសេសដែលអនុញ្ញាតអោយអ្នក ផ្ទុកនូវតំលៃបានច្រើននៅក្នុង variable មួយ ។ រាល់តំលៃនិមួយៗត្រូវបានរក្សាទុកនៅក្នុង index របស់ array ដែលអាច ជាលេខ ឬ ជា តួអក្សរ ។ ជា default ធាតុរបស់ array ដែលជា index គឺចាប់ផ្តើមពីលេខ 0 ។ ហេតុអ្វីបានជាត្រូវប្រើប្រាស់ array ?

ប្រសិនបើអ្នកមានតំលៃចំនួន ៥ ដែលត្រូវរក្សារទុក នោះអ្នកប្រាកដជាត្រូវបង្កើត variable ចំនួនប្រាំផងដែរ**Array** គឺ flexible ព្រោះវាអាចផ្ទុកតំលៃបានពីរ ឬ ពីររយ តំលៃ ដោយពុំមានការង្កើតនូវvariableថ្មីទៀតហើយ array ក៏អាចអោយអ្នកធ្វើការជាមួយតំលៃរបស់វា បានយ៉ាងងាយ ដូចជា ការ loop ធាតុរបស់ array និមួយៗ ឬ តំរាបធាតុរបស់វាទៅលំដាប់នៃលេខរៀង ឬ ជាតួអក្សរ ទៅតាមការកំនត់នៅក្នុង system របស់អ្នក ។ ខាងក្រោមគឺជាការបង្ហាញនូវធាតុរបស់ users array ដែលមានធាតុទី៤ ជា index ទី៣ នៃ users ។

| The Elements in the `users` Array | | |
|---|---|---|
| **Index Number** | **Value** | **Which Element?** |
| 0 | Sok | First |
| 1 | Sao | Second |
| 2 | Setha | Third |
| 3 | Mesa | Fourth |

PHP ក៏បានផ្តល់នូវលទ្ធភាពដើម្បីរៀបចំនូវ indexed របស់ array ដោយការប្រើប្រាស់ទាំង លេខ និង អក្សរផងដែរ ។

## 2. Creating Arrays

អ្នកអាចបង្កើតនូវ array variable ដោយប្រើវិធីពីរយ៉ាងគឺ ការប្រើប្រាស់ array() construct ឬ ការប្រើប្រាស់នូវសញ្ញា square brackets ( [ ] ) ។

### 2.1 Defining Arrays with the `array()` Construct.

array()construct វាមានសារៈប្រយោជន៏នៅពេលដែលអ្នកចង់ផ្តល់តំលៃច្រើនទៅអោយ array ក្នុងពេលតែមួយ ។ ខាងក្រោមគឺឧទាហរណ៏នៃការបង្កើត array មួយដែលមានឈ្មោះថា $users ហើយយើងបានផ្តល់តំលៃជា string ចំនួនបួនតំលៃទៅអោយវា ។

```
$users = array ("Sok", "Sao", "Mata", "Mesa");
```

ឥឡូវនេះអ្នកអាចយកធាតុរបស់ $users មកប្រើប្រាស់ដោយការប្រើប្រាស់ index របស់ array

```
print $users[2];
```

លទ្ធផលនៃឧទាហរណ៍ខាងលើនឹង បង្ហាញជាអក្សរ Mata ដែល index របស់វាហើយត្រូវបានដាក់នៅចន្លោះ square brackets ( [2] ) បន្ទាប់ពីឈ្មោះរបស់ array ( $users ) ។

**2.2 Defining or Adding to Arrays with the Array Identifier.**

អ្នកអាចបង្កើត array ថ្មី ឬ បន្ថែមតំលៃទៅអោយ array បានដោយការប្រើប្រាស់នូវ **array Identifier** ។ array identifier គឺជាបន្ទុំនៃ squre brackets និង index របស់វា ជាលេខ ឬ ជាឈ្មោះ ។ខាងក្រោមជា ឧទាហរណ៍នៃការបង្កើត $users array ដោយប្រើវិធីសាស្ត្រមួយផ្សេងទៀត ។

```
$users[] = " Sok";
$users[] = " Sao";
$users[] = " Dara";
$users[] = " Mesa";
```

ឧទាហរណ៍ខាងលើមិនទាមទារអោយអ្នកដាក់នូវតំលៃលេខដែលជា index នៅចន្លោះ square Brackets នោះឡើយ ព្រោះ PHP នឹងផ្តល់តំលៃ index ដោយស្វ័យប្រវត្តិទៅអោយ array ។ ម្យ៉ាងវិញទៀតអ្នកក៏អាចដាក់នូវតំលៃជា index របស់ array បានផងដែរ ប៉ុន្តែមិនមានការគាំទ្រអោយធ្វើបែបនេះនោះទេសូមពិនិត្យមើល ការសរសេរកូដខាងក្រោម:

```
$users[0] = "Phanit";
$users[200] = "Ratana";
```

Array ខាងលើមានធាតុត្រឹមតែពីរប៉ុណ្ណោះ ប៉ុន្តែ index ចុងក្រោយរបស់វាគឺជា index ទី២០០ PHP នឹងមិនកំនត់តំលៃធាតុទៅអោយ index ដែលនៅចន្លោះ នោះឡើយ ដែលធ្វើអោយមានការភាន់ច្រឡំនៅពេលដែលចង់ព្យាយាមយកធាតុដែលមានក្នុង array នោះមកប្រើ ខណៈពេលដែលអ្នកចង់ប្រើនូវ ធាតុរបស់វា ណាមួយទៅតាមចិត្តរបស់អ្នក។ សំរាប់ការបង្កើត array អ្នកអាចប្រើ នូវ array() contstructរួចប្រើនូវ array identifier ដើម្បីបន្ថែមនូវធាតុថ្មីទៀតក៏បាន ។

សូមពិនិត្យឧទាហរណ៍ខាងក្រោម :

```
$users = array ("Sok", "Sao", "Mata", "Mesa");
$users[] = "Menear";
```

**3. Populating an Array with array_fill()**

ប្រសិនបើអ្នកចង់ដាក់នូវតំលៃជា default នៅចន្លោះនៃ index array នោះអ្នកប្រហែលជាប្រើនូវ array() function ដូចខាងក្រោម ។

$member = array ("cambodia", "cambodia", "cambodia","cambodia "); ឬ អ្នកអាចប្រើប្រាស់នូវ array ម្យ៉ាងទៀតដូចជា

```
$member[] = "Cambodia";
$member[] = "Cambodia";
$member[] = "Cambodia";
$member[] = "Cambodia";
```

PHP បានផ្តល់នូវ function ដើម្បីដោះស្រាយនូវបញ្ហានេះដោយប្រើនូវ array_fill() function ដែលតំរូវអោយអ្នកផ្តល់នូវ arguments ចំនួន៣សំរាប់ function នេះ ទី១គឺជាតំលៃ index ដែលចាប់ផ្តើម

ទីពីគឺជា ចំនួនធាតុដែលអ្នកចង់បាន ហើយ argument ទី៣ គឺជាតំលៃដែលអ្នកត្រូវផ្តល់អោយជាធាតុរបស់Array ។

ដោយការប្រើប្រាស់នូវ array_fill() function អ្នកអាចសរសេរនូវបំណែកកូដខាងលើឡើងវិញ ដូចខាងក្រោម :

```
$member = array_fill( 0, 4, "Cambodia" );
```

ឧទាហរណ៍: ២៤

```
<?
$member = array_fill(0,4,"Cambodia");
$member[] = "Malaysia";
print $users[2];
?>
```

## 4. Associative Arrays

**Assosciate** array គឺជា array ដែលប្រើប្រាស់នូវ index ជាអក្សរនៅ ចន្លោះ squqre brakets អ្នកអាចបង្កើតនូវ assosciate array ដោយ array construct( array() )ឬ array identifier (array[])

**ឧទាហរណ៍**

```
$character = array("name" => "Sok",
                   "occupation" => "Student",
                   "age" => 12,
                   "Adr" => "Phnom Pehn" );
```

ឥឡូវនេះយើងអាចប្រើប្រាស់នូវធាតុ array របស់ $character ដូចខាងក្រោម:

```
print $character['occupation'];
```

keys ដែលនៅក្នុង assosciate array គឺជា string ដូច្នេះ engine នឹងបង្ហាញរបាយការណ៍ error ប្រសិនបើ keys នៃ array មិនមាន quoted ។ ដូច្នេះអ្នកគួរតែប្រើនូវ quotation marks នៅពេលដែលអ្នកប្រើkeys នៃ array ជា string ។

```
print $character[occupation]; // មិនត្រឹមត្រូវ
print $character["occupation"]; // ត្រឹមត្រូវ
```

ប្រសិនបើ key ត្រូវផ្ទុកនៅក្នុង variable នោះ អ្នកមិនចាំបាច់ត្រូវប្រើ quotation mark នោះឡើយ ។

```
$occ = "occupation";
print $character[$occ]; // ត្រឹមត្រូវ
```

### 4.1 Directly Defining or Adding to an Associative Array

អ្នកអាចបង្កើត ឬ បន្ថែម ឈ្មោះ/តំលៃ ទៅអោយ associate array ដោយការផ្តល់នូវតំលៃទៅអោយឈ្មោះនៃធាតុរបស់ array ដូចខាងក្រោម ។

```
$character["name"] = "sok";
$character["occupation"] = "Programmer";
$character["age"] = 30;
$character["address"] = "Phnom Penh";
```

## 5. Getting the Size of an Array

count() function ផ្តល់នូវចំនួនធាតុរបស់ array ដែលមាន បំណែកកូដខាងក្រោមយើងបានប្រើប្រាស់ នូវ count()function ដើម្បីយកធាតុចុងក្រោយនៃ array $users មកប្រើ ។

```
$users = array ("Sambath", "Ratana", "Davy", "Ryda" );

print $users[count($users)-1];
```

ឧទាហរណ៍ ២៦

```
<html>
<body>
<head>
<title>Getting size of array</title>

<body>
<h2>Getting size of array</h2>

<?php

$users[]="Sok";
$users[]="Som";
$users[]="Mom";
$users[]="Mab";

print "<br/>".count($users);

?>
</body>
</html>
```

***ចំណាំ :*** count() ផ្តល់តំលៃនៃចំនួនសរុបរបស់ធាតុ array មិនមែនជាតំលៃនៃ index ចុងក្រោយនោះទេ ។

ឧទាហរណ៍ខាងក្រោមនេះគឺការបង្កើត array ដោយការផ្តល់នូវ index ទៅអោយ array ដោយខ្លួនអ្នក

```
$users[35] ="Sok";
$users[52] ="Som";
$users[890] ="Mom";
$users[52]="Mab";
```

count() នៅតែផ្តល់នូវចំនួនសរុបនៃធាតុ array ដដែល គឺមានចំនួន ៤ ធាតុ ។ ហើយអ្នកក៏អាចទទួលនូវធាតុរបស់ array ចុងក្រោយបានដោយការប្រើនូវ end() function ដែលទាមទារត្រឹមតែ argument មួយ ប៉ុណ្ណោះ ។ ឧទាហរណ៍ print end($users);

## 6. Looping Through an Array

foreach statement គឺជាវិធីសាស្ត្រមួយយ៉ាងប្រសើរដើម្បី loop រាល់ធាតុនិមួយៗដែលមាននៅ ក្នុង array ។ អ្នកអាចប្រើប្រាស់នូវ foreach statement ដូចខាងក្រោម :

```
foreach( $arr as $temp )
{
 //…………

}
```

$arr គឺជា array ដែលអ្នកត្រូវ loop ហើយ $temp គឺជា variableដែលអ្នកនឹងត្រូវរក្សារទុកជាបណ្តោះអាសន្ន នូវធាតុនិមួយៗ ក្នុងគ្រា loop ។ កូដខាងក្រោមគឺជាការបង្កើត array មួយហើយយើង ប្រើ foreach statement ដើម្បីយកធាតុនិមួយៗមក បង្ហាញលើ browser ។

ឧទាហរណ៍ ២៦

```
<html>
<head>
<title>Looping throught array</title>
</head>

<body>
<h2>Looping througth array</h2>

<?php

$users = array ("Sok", "Som", "Mab", "Mab" );

foreach ( $users as $val )
{
print "$val<br />";
}

?>

</body>
</html>
```

ឧទាហរណ៍ ២៧

```
<html>
<head>
<title>Looping throught array</title>
</head>

<body>
<h2>Looping througth array</h2>

<?php

$users[]="Sok";
$users[]="Som";
$users[]="Mom";
$users[]="Mab";

foreach( $user as $val )
{
print "$val<br/>
}

?>

</body>
</html>
```

### 6.1 Looping Through an Associative Array

ដើម្បីប្រើប្រាស់នូវ foreach statement ជាមួយ assosciat array ទាំង keys និង values អ្នកអាចប្រើប្រាស់ជាមួយនឹង foreach statement ដូចខាងក្រោម :

```
foreach( $arr as $key=>$value )
{
  //.....
}
```

$arr គឺជា array ដែលយើងនឹងត្រូវ loop ហើយ $key គឺជា variable ដែលផ្ទុកនូវ key និមួយៗជាបណ្តោះអាសន្ន ហើយ $val គឺជា variable ដែលផ្ទុកនូវ value របស់ array និមួយៗជាបណ្តោះអាសន្នក្នុងគ្រា loop ម្តងៗ ។

ឧទហរណ៏ ២៨

```
01:     <html>
02:     <head>
03:     <title>Looping thought associate array</title>
04:     </head>
05:     <body>
06:     <h2> Looping thought associate array</h2>
07:
08:     <?php
09:
10:     $character = array ("name" => "Sao",
11:                         "occupation" => "Student",
12:                         "age" => 12,
13:                         "Adr" => "Phnom Pehn");
14:
15:     foreach ( $character as $key=>$val )
16:     {
17:     print "$key = $val<br />";
18:     }
19:
20:     ?>
21:
22:     </body>
23:     </html>
```

Arrayដែលបានបង្កើតនៅបន្ទាត់ទី១១ ហើយប្រើប្រាស់នូវ foreach statement នៅបន្ទាត់ទី ១៥ ដើម្បី loop នូវធាតុដែលជាតំលៃ និង key របស់វា ។ រាល់ key និមួយត្រូវបានផ្ទុកនៅក្នុង variable ដែលផ្តល់ឈ្មោះអោយថា $key និង រាល់ value និមួយៗត្រូវបានផ្ទុកនៅក្នុង variable ដែលផ្តល់ឈ្មោះថា $val ហើយត្រូវបានបង្ហាញជាលទ្ធផលទៅកាន់ browser នៅបន្ទាត់ទី ១៧ ។



## 7. Joining Two Arrays with array_merge()

array_merge() មានតួនាទីផ្គុំនូវធាតុរបស់ array ពីរ ឬ array ច្រើនបញ្ចូលគ្នា រួចផ្តល់ជា Array ថ្មីមួយទៀតដែលជាបន្តុំនៃធាតុ array ទាំងអស់នោះ ។ ឧទាហរណ៍ខាងក្រោមគឺជាឧទាហរណ៍នៃការបង្កើតនូវ array ពីរ គឺ array $arr1 និង array $arr2 ហើយធ្វើការបញ្ចូលគ្នារវាងធាតុនៃ array ទាំងពីររួចផ្តល់តំលៃទាំងនោះទៅអោយ $arr3 បន្ទាប់មក loop រាល់ធាតុដែលមាននៅក្នុង $arr3 ។

### ឧទាហរណ៍ ២៩

array_merge.php

```
<html>
<head>
<title>Joining Two array with array_merge()</title>
</head>

<body>
<h2>Using array_merge()</h2>

<?php

$arr1 = array("a", "b", "c");
$arr2 = array(1,2,3);
$arr3 = array_merge( $arr1,$arr2 );

foreach ( $arr3 as $val )
{
print "$val<br />";
}

?>

</body>
</html>
```

$arr3 array ផ្ទុកនូវរាល់ធាតុដែលមាននៅក្នុង $arr1 និង $arr2 array ។ foreach statement នឹងបង្ហាញនូវបន្តុំនៃធាតុ array ( 'a', 'b', 'c', 1, 2, 3 ) ជាមួយនឹង <br/> នៅចន្លោះធាតុនិមួយៗ ។

## 8. Adding Multiple Variables to an Array

array_push()ទទួលយកនូវ array និង តំលៃផ្សេងពី parameters ដែលតំលៃទាំងនោះគឺជាធាតុដែលនឹងត្រូវបន្ថែមទៅអោយ array ។ array_push() function មិនមានលក្ខណៈដូច array_merge() នោះទេ ពីព្រោះ array ដែលបញ្ជូនទៅជា argument ដំបូងនឹងត្រូវប្រែប្រួល ហើយ array_push() នឹង ផ្តល់មកវិញនូវតំលៃសរុបទាំងអស់ដែលមាននៅក្នុង array នោះវិញ ។

**ឧទាហរណ៍ ៣០**

```
01:	<html>
02:	<head><title>Adding Muliple variables to an Array</title></head>
04:	<body>
05:
06:	<?php
07:
08:	$arr1 = array ("a", "b", "c");
09:	$total = array_push( $arr1,1,2,3);
10:	print  "There are $total elements in \$arr1 ";
11:
12:	foreach ( $arr1 as $val )
13:	{
14:	print  "$val<br/>";
15:	}
16:
17:	?>
18:
19:	</body>
20:	</html>
```

ឥឡូវនេះ `$arr1` បានបន្ថែមនូវធាតុជា integer ចំនួនបីធាតុ ដែលបានមកពីការប្រើប្រាស់នូវ array_push() function ដូច្នេះ `$arr1` ផ្ទុកនូវតំលៃសរុបចំនួន ៦ ធាតុហើយត្រូវបានបង្ហាញនូវធាតុនិមួយៗទៅកាន់ browser ដោយកូដដែលមាននៅក្នុង foreach statement ។

***ចំណាំ:*** យើងបានប្រើនូវ backslash ពេលដែល print ជា string `"------\$arr1"` នៅបន្ទាត់ទី ១០

ប្រសិនបើអ្នកប្រើនូវ និមិត្តសញ្ញានៅពីមុខពាក្យ ឬ ឃ្លាណាមួយនោះ PHP នឹងបញ្ចូលជាតំលៃទៅអោយទៅតាមឈ្មោះ variable ។ ឧទាហរណ៍ ខាងលើយើងចង់បង្ហាញនូវ string `'$arr1'` ដែលមិនមែនជាតំលៃរបស់ variable នោះទេ ដូច្នេះដើម្បី print នូវ special character (`$`) យើងត្រូវតែប្រើនូវ backslash (\)

នៅពីមុខ ។ ប្រសិនបើអ្នកចង់បន្ថែមធាតុទៅអោយ `array` ហើយជាធាតុដំបូងទៀតនោះ អ្នកអាចប្រើប្រាស់ជាមួយនឹង `array_unsift()` ។

**ឧទាហរណ៍ ៣១**

```
<html>
<head>
<title>Using array_unsift() </title>
</head>

<body>
<h2>Using array_unsift()</h2>

<?php
```

```
$arr1 = array ("a", "b", "c");
$total = array_unshift( $arr1, 1, 2, 3 );
print  "There are $total elements in \$arr1 ";

foreach ( $arr1 as $val )
{
print  "$val<br/>";
}
:
?>
</body>
</html>
```

ឥឡូវនេះ $arr1 array ផ្ទុកនូវតំលៃ 1, 2, 3, "a", "b", "c"  ។

## 9. Removing the First Element of an Array with array_shift()

array_shift() មានតួនាទីយកចេញនូវធាតុទីមួយនៃ array  ។សូមពិនិត្យ ឧទាហរណ៍ខាងក្រោម:

**ឧទាហរណ៍ ៣២**

```
<html>
<head>
<title>Remove first array element with array_shift()</title>
</head>
<body>
<h2>Using array_shift()</h2>

<?php

$user=array("M","U","T","H");
$total=count($user);
echo "Before use array_shift() threre are $total element<br/>";

foreach($user as $val)
{
echo "$val <br/>";
}

array_shift($user);
$total=count($user);
echo "after use array_shift() there are $total element</br>";

foreach($user as $val)
{
print "$val <br/>";
}

?>
```



```
</body>
</html>
```

## 10. Slicing Arrays with array_slice()

array_slice() អនុញ្ញាតអោយអ្នកទាញយកចំនួននៃធាតុ array ដែលទាមទារអោយអ្នកផ្តល់នូវ argument ចំនួនបី ទីមួយគឺជា array variable ទី២ជាទីតាំងដែលត្រូវចាប់ផ្តើមយក និងទីបី គឺជាចំនួនធាតុ របស់ array ដែលត្រូវការហើយ argument ទីបីនេះគឺ (optional) ប្រសិនបើអ្នកមិនប្រើនូវ argument នេះទេ array_slice() និងចាប់យកនូវធាតុទាំងអស់នៃ array ចាប់ពីទីតាំងដែលអ្នកបានផ្តល់ជាតំលៃនៅ ក្នុង argument ទី១មក ។

### ឧទាហរណ៍ ៣៣

```
<html>
<head><title>Using array_slice()</title>
</head>
<body>
<h2>Using array_slice()</h2>

<?php

$first = array ("a", "b", "c", "d", "e", "f");
$second = array_slice($first, 2, 3);

foreach ( $second as $val )
{
 print "$val<br />";
}

?>

</body>
</html>
```

កូដដែលបង្កើតនៅឧទាហរណ៍ ៣៣ នឹងបង្ហាញនូវលទ្ធផល 'c', 'd', និង 'e' ដែលជាធាតុរបស់ $secend បន្ទាប់ពីប្រើនូវ array_slice() ដោយយកធាតុទាំងអស់របស់ $first ។

## 11. Sorting Arrays

### 11.1 Sorting Numerically Indexed Arrays with sort()

sort() ទទួលយកនូវ argument មួយដែលជា array ហើយធ្វើការតំរៀបវាទៅតាមលំដាប់នៃតួ អក្សរឬពីតូចទៅធំ ឧទាហរណ៍ ៣៤ គឺជាការបង្កើត array ដោយផ្តល់នូវតំលៃជា string ទៅអោយបន្ទាប់មកយើងប្រើ sort() ដើម្បីតំរៀបធាតុទាំងនោះពី A-Z ឬ ពីតូចទៅធំ រួចបង្ហាញជាលទ្ធផលទៅកាន់ Browser ។

**សូមពិនិត្យក្នុងឧទាហរណ៍ ៣៤**

```
<html>
<head><title> sorting array with sort() function</title>
</head>
<body>
<h2>Using sort() function </h2>

<?php

$s_array = array ("Bayon", "Taprom", "Angkor", "Presh vihear");
sort( $s_array );

foreach ( $s_array as $var )
{
print "$var<br />";
}

?>
</body>
</html>
```

អ្នកក៏អាចផ្លាស់ប្តូរនូវលំដាប់នៃការតំរៀបធាតុរបស់ array ពីលំដាប់ តូចទៅធំ ឬ ពីលំដាប់ធំ ទៅតូចវិញដោយការប្រើនូវ rsort() ។ សូមកុំព្យាយាមប្រើ sort()ឬ rsort() ជាមួយ associate array ពីព្រោះ វានឹងធ្វើអោយអ្នកបាត់បង់នូវ key របស់ array ។

## 11.2 Sorting an Associative Array by Value with asort()

assort() ទទួលយក argument ដែលជាប្រភេទ associate array ហើយធ្វើការតំរៀបតំលៃ របស់ array នោះពី A-Z ឬ ជាតំលៃលេខ ពីតូចទៅធំ អាស្រ័យទៅលើប្រភេទនៃតំលៃ ។

ឧទាហរណ៍ ៣៥

```
<html>
<head><title> sorting an associate array by value with assort() </title>
<head>
<body>
<h2>sorting an associate array by value with assort()</h2>

<?php

$first = array("Cocacola"=>3,"Pepsi"=>2,"Fanta"=>1);
echo "<b>an associate Array before use asort </b> <br/>";

foreach ( $first as $key => $val )
{
```

```
print "$key = $val<br />";
}
echo "<b>an associate Array after asort </b><br/>";
asort( $first );

foreach ( $first as $key => $val )
{
print "$key = $val<br />";
}

?>

</body>
<html>
```




សំរាប់ការប្តូរលំដាប់នៃការតំរៀបពីតូចទៅធំ ឬ ពីធំទៅតូច អ្នកអាចប្រើនូវ **arsort()** ។

### 11.3 Sorting an Associative Array by Key with ksort()

ksort() ទទួលនូវ argument ដែលជា associate array ហើយធ្វើការតំរៀបតំលៃ របស់វា និមួយៗទៅតាមលំដាប់ពី A-Z ឬ ជាលេខ ពីធំទៅតូច ដោយអាស្រ័យទៅលើ key របស់ array នោះ ។

ឧទាហរណ៍ ៣៦

```
<html>
<head><title> sorting an associate array by key with assort() </title>
<head>
<body>
<h2>sorting an associate array by key with kssort()</h2>

<?php

$first = array("Cocacola"=>3,"Pepsi"=>2,"Fanta"=>1);
echo "<b>an associate Array before use ksort </b> <br/>";

foreach ( $first as $key => $val )
{
print "$key = $val<br />";
}
echo "<b>an associate Array after use ksort </b><br/>";
ksort( $first );
foreach ( $first as $key => $val )
{
print "$key = $val<br />";
}
?>
</body>
<html>
```

អ្នកក៏អាចផ្លាស់ប្តូរលំដាប់នៃការតំរៀប ពីធំទៅតូច ឬ ពី Z-A វិញដោយប្រើ **krsort()** ។



# មេរៀនទី ៦ Object

## 1. What Is an Object ?

**Object** គឺជា បណ្តុំនៃ variables និង functions ដែលឋិតនៅក្នុង template ពិសេសមួយដែល គេហៅថា class ។ object លាក់នូវតំណើរការដែលមាននៅខាងក្នុង ពីការប្រើប្រាស់វា ដោយផ្តល់ជា Interface សំរាប់អោយអ្នកបញ្ជូននូវ បញ្ហារដើម្បីទទួលពតិមានត្រលប់មកវិញ ។ interface ទាំងនោះគឺជា Function ពិសេសដែលគេអោយឈ្មោះ methods ហើយរាល់ methods ទាំងអស់នៃ object គឺត្រូវតែ Access ទៅកាន់ special variable ហៅថា properties ។

